# III- រាជរដ្ឋាភិបាល

## អនុក្រឹត្យ

## អនុក្រឹត្យលេខ ០១ អនក្រ.បក

## ស្តីពីការបែងចែកចំណូលថវិកាទូទៅរបស់រដ្ឋ

## តាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ២០០១

===

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នា១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ហើយត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែល ប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ ១៩៩៩

-បានឃើញព្រះរាជក្រម នស/រកម/១២០០/១២ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ២០០១

-តាមការចាំបាច់របស់រាជរដ្ឋាភិបាល

### សម្រេច

**មាត្រា ១.-**

ចំណូលជាប្រចាំ និងជាមូលធននៃថវិកាទូទៅរបស់រដ្ឋ ដែលមានចែងនៅក្នុងច្បាប់ ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ២០០១ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម នស/រកម/១២០០/១២ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០០ ត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែល នីមួយៗ និងទៅតាមជំពូកនៃថវិកា ដូចមានចែងក្នុងតារាង ដែលជូនភ្ជាប់ជាមួយ អនុក្រឹត្យនេះ ។

**មាត្រា ២.-**

ចំណូលត្រូវបានប្រមូលដើម្បីជាគុណប្រយោជន៍ ដល់ថវិកាទូទៅរបស់រដ្ឋ និងស្ថិតនៅក្រោមការ ត្រួតពិនិត្យរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ការបែងចែកចំណូល នៃជំពូកទាំងនេះ តាម ប្រការ កថាខ័ណ្ឌ និងវាក្យខ័ណ្ឌ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការ គ្រប់រដ្ឋលេខាធិការដ្ឋាន អភិបាលគ្រប់ខេត្ត-ក្រុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ២០០១ តទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែមករា ឆ្នាំ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយរដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

ហត្ថលេខា

**គាត ឈន់**

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

***